ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៦២ គកសរ កសក

# សេចក្តីសម្រេច
# ស្តីពី

## ការបង្កើត និងចាត់តាំងសមាសភាពក្រុមការងារអនុវត្តសមាសភាគទី១ (CMU1) "ការគ្រប់គ្រងធនធានជលផលតំបន់ទាបទន្លេសាបនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង" នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៤ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមកិច្ចព្រមព្រៀងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយធនាគារពិភពលោក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥)២៣-២១៧ ៣២០
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

## សម្រេច

**ប្រការ១** : ត្រូវបានបង្កើតក្រុមការងារអនុវត្តសមាសភាគទី១ (CMU1) "ការគ្រប់គ្រងធនធានជលផលភូមិភាគល្បសាន នៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង" នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ដូចមានសមាសភាព ខាងក្រោម៖

| | | |
|---|---|---|
| ១-លោក ឆេង ផែន | ប្រធានស្តីទីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប | ប្រធាន |
| ២-លោក ទូច ប៊ុនថង | អនុប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប | អនុប្រធាន |
| ៣-លោក លី វុទ្ធី | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ | សមាជិក |
| ៤-លោក ជិន ដា | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម | សមាជិក |
| ៥-លោក ហេង សុវណ្ណារ៉ា | អនុប្រធាននាយកដ្ឋានអភិរក្សជលផល | សមាជិក |
| ៦-លោក ឡេង ស៊ីវណ្ណ | អនុប្រធាននាយកដ្ឋានអភិរក្សជលផល | សមាជិក |
| ៧-លោកស្រី ស៊ឹម ថាវី | អនុប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប | សមាជិកា |
| ៨-លោក ង៉ោ ប៉េងប៊ុន | ប្រធានការិយាល័យតាមដាននិងវាយតម្លៃនៃនាយកដ្ឋាន ផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩-លោក អ៊ុំ សារី | អនុប្រធានការិយាល័យរដ្ឋបាលនៃវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍ជលផលទឹកសាប | សមាជិក |
| ១០-កញ្ញា ទិត ពុទ្ធារ័ត្ន | មន្ត្រីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប | សមាជិកា |

**ប្រការ២** : ក្រុមការងារអនុវត្តសមាសភាគទី១ (CMU1) "ការគ្រប់គ្រងធនធានជលផលភូមិភាគល្បសាននៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង" នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ មានភារកិច្ចដូចខាងក្រោម៖

- អនុវត្តសមាសភាគទី១"ការគ្រប់គ្រងធនធានជលផលភូមិភាគល្បសាននៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង" នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ ទៅតាមឯកសារគម្រោងដែលបានព្រមព្រៀងរវាងភាគី កម្ពុជានិងធនាគារពិភពលោក ក្នុងកិច្ចចរចាដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ រួមមាន កិច្ចការរដ្ឋបាល គ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគម្រោង
- សម្របសម្រួលជាមួយខេត្តគោលដៅរបស់គម្រោងដើម្បីអនុវត្តសកម្មភាពគម្រោង
- អនុវត្តសកម្មភាពត្រួតពិនិត្យតាមដានគម្រោងដោយធានាឱ្យមានអភិបាលកិច្ចល្អ
- សហការជាមួយសមាសភាគទី២ "ការគ្រប់គ្រងធនធានទឹកចម្រុះភូមិភាគល្បសាន ៣S និង៤P (CMU2)" នៃគម្រោងគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ (Mekong Integrated Water Resources Management, M-IWRM/MK3)
- ធ្វើបច្ចុប្បន្នភាព វឌ្ឍនភាពសកម្មភាពរបស់គម្រោងជារៀងរាល់ខែជូនប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួល បន្ទុកជាប្រធានរដ្ឋបាលជលផល
- ធ្វើបច្ចុប្បន្នភាព វឌ្ឍនភាពការងាររបស់គម្រោងជូនក្រុមប្រឹក្សាភិបាលគម្រោងទៅតាមតម្រូវការ
- ទទួលខុសត្រូវគ្រប់កិច្ចការរបស់អនុគម្រោងចំពោះមុខក្រុមប្រឹក្សាភិបាលគម្រោង រៀបចំរបាយការណ៍ ហិរញ្ញវត្ថុ និងរបាយការណ៍បញ្ចប់គម្រោងជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

4

**ប្រការ៣** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល** :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងមុខងារសាធារណៈ

-សាលាខេត្តពាក់ព័ន្ធ

-ធនាគារពិភពលោក

-ដូចក្នុងប្រការ៣

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ